00607675

លេខ/No: D427/1/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ ៧៥)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 17 / 09 / 2010
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [illegible]

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public CR

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើជាបន្ទាន់របស់ អៀង សារី សុំបង្កើនចំនួនទំព័រកំណត់ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការ ដែលបានលើកឡើងដោយនៅក្នុងដីកាដំណោះស្រាយ**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន</u>៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ផុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម Rowan DOWNING

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 21 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្ដី") លោក **អៀង សារី** ស្វែងរកការបង្កើនចំនួនទំព័រឱ្យលើសពី៣០ទំព័រកំណត់ដែលកំពុងអនុវត្ត[1] ដើម្បីដាក់បណ្ដឹងឧទ្ធរណ៍មួយប្រឆាំងនឹងផ្នែកជាច្រើននៃដីកាដំណោះស្រាយ[2] ដែលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក[3]។ ដោយសារតែវិធានផ្ទៃក្នុងមិនហាមឃាត់មេធាវីការពារក្ដីក្នុងការដាក់បណ្ដឹងឧទ្ធរណ៍ដាច់ដោយឡែកទាក់ទងទៅនឹងបញ្ហាយុត្តាធិការនីមួយៗ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ដែលបណ្ដឹងឧទ្ធរណ៍នីមួយៗមានកម្រាស់៣០ទំព័រ និងដើម្បីជាផលប្រយោជន៍នៃការចំណាយរបស់តុលាការអស់តិច ទើបមេធាវីការពារក្ដីមានបំណងដាក់បណ្ដឹងដែលលើកឡើងនូវបញ្ហាយុត្តាធិការទាំងអស់ទៅក្នុងបណ្ដឹងតែមួយ ។ ការធ្វើដូច្នេះនឹងតម្រូវឱ្យបង្កើនចំនួនទំព័រកំណត់ ។ អនុលោមទៅតាមមាត្រា ៥.៤ នៃសេចក្ដីណែនាំអនុវត្ត ស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក វាជាអំណាចរបស់អង្គបុរេជំនុំជម្រះក្នុងការបង្កើនចំនួនទំព័រឱ្យលើស៣០ទំព័រកំណត់ ដែលកំពុងអនុវត្តនៅក្នុងកាលៈទេសៈពិសេស។ កាលៈទេសៈពិសេសនេះ មាននៅក្នុងករណីនេះ ។ ដីកាដំណោះស្រាយលើកឡើងនូវបញ្ហាយុត្តាធិការជាច្រើន ដូចជាសុពលភាពគតិយុត្តិនៃព្រះរាជក្រឹត្យលើកលែងលោក អៀង សារី, ថាតើគោលការណ៍មិនជម្រះក្ដីពីរដង (*ne bis in idem*) គឺជាការហាមឃាត់មិនឱ្យមានការកាត់ក្ដីដែរ ឬទេ និងថាតើ អវតក មានយុត្តាធិការលើលោក អៀង សារី ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ បទល្មើសក្រោមច្បាប់ជាតិ និងការទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌជាថ្នាក់លើ ដែរ ឬទេ ។ បញ្ហានីមួយៗទាំងនេះគឺពិតជាស្មុគ្រស្មាញ ហើយបញ្ហានីមួយៗសឹងតែប្រើអស់៣០ទំព័រទៅហើយ បើសិនជាសំណើសុំបង្កើនចំនួនទំព័រនេះមិនត្រូវបានអនុញ្ញាតនោះ ។ មេធាវីការពារក្ដីមិនអាចដោះស្រាយនូវបញ្ហានីមួយៗទាំងនេះឱ្យបានពេញលេញនៅក្នុងបណ្ដឹងឧទ្ធរណ៍ ដែលមានកម្រាស់ ៣០ ទំព័រនោះបានទេ ដូច្នេះហើយមេធាវីការពារក្ដីមិនអាចបំរើឱ្យអស់ពីចិត្តនូវផលប្រយោជន៍របស់លោក អៀង សារី បានទេ ប្រសិនបើមេធាវី

---

[1] មាត្រា ៥.២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅអ.វ.ត.ក ចែងថា "ឯកសារដាក់អង្គបុរេជំនុំជម្រះ ឬ អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក មិនត្រូវលើសពី៣០ទំព័រជាភាសាអង់គ្លេស ឬ ភាសា បារាំង ឬ៦០ទំព័រជាភាសាខ្មែរ លើកលែងតែមានប្បញ្ញត្តិចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង ឬ សេចក្ដីណែនាំ អនុវត្តនេះ ឬបទបញ្ជាចេញដោយ អ.វ.ត.ក ។

[2] រឿងក្ដី នួន ជា សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ កញ្ញា ២០១០ ឯកសារលេខ D427, ERN: 00604508-00605246។

[3] បណ្ដឹងឧទ្ធរណ៍នេះត្រូវបានអនុញ្ញាតិ ដោយអនុលោមទៅតាមវិធាន ៧៤(៣)(ក) ដែលអនុញ្ញាតិឱ្យជនត្រូវចោទប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬ សេចក្ដីសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតដែលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក ។ ចំនុចនេះនឹងពន្យល់ឱ្យបានពេញលេញនៅក្នុងបណ្ដឹងឧទ្ធរណ៍ ។

00607677



ការពារក្តីប៉ុនប៉ងធ្វើយ៉ាងដូច្នេះមែន[4] ។

ដូច្នេះ យោងតាមមូលហេតុដែលបានគូសបញ្ជាក់នៅក្នុងសំណើ មេធាវីការពារក្តីស្នើសុំដោយសេចក្តីគោរព ដល់អង្គបុរេជំនុំជម្រះ បង្កើនចំនួនទំព័រកំណត់សម្រាប់ចម្លើយតបនេះ រហូតដល់១៨០ទំព័រ ។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

[4] សហមេធាវីការពារក្តីបានករណីយកិច្ចការពារក្តីលោក អៀង សារី ប្រកបដោយការយកចិត្តទុកដាក់អស់ពីចិត្ត ។ កាតព្វកិច្ចនេះតម្រូវឲ្យមេធាវីការពារក្តីការពារសិទ្ធិ និងផលប្រយោជន៍របស់លោក អៀង សារី ដោយយកចិត្តទុកដាក់អស់ពីចិត្តពីថ្លើម ហើយមេធាវីការពារក្តីត្រូវតែធ្វើយ៉ាងដូច្នេះ ដើម្បីធានាថាការជំនុំជម្រះក្តីរបស់គាត់ គឺប្រកបដោយយុត្តិធម៌ ។ ទាក់ទងទៅនឹងសិទ្ធិទទួលបានពេលវេលានិងមធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំការពារក្តី ការពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃការយកចិត្តទុកដាក់ឲ្យអស់ពីចិត្ត មានអ្នកប្រវត្តិវិទូម្នាក់បានកត់សំគាល់ថា "ទាក់ទងទៅនឹងពេលវេលានិងមធ្យោបាយគ្រប់គ្រាន់ កម្រិតនៃការយកចិត្តទុកដាក់ជាក់លាក់របស់មេធាវីការពារក្តី គឺត្រូវបានគេរំពឹងទុក និងជាសេចក្តីត្រូវការចាំបាច់ ។ <u>មេធាវីការពារក្តីអាចតវ៉ាពីការរំលោភសិទ្ធិរបស់ខ្លួន ប្រសិនបើពួកគេបានធ្វើអ្វីគ្រប់បែបយ៉ាង</u>ដែលតម្រូវដោយច្បាប់ក្នុងស្រុក ដើម្បីទទួលបានការ (ពន្យារ) ពេលវេលា ឬ មធ្យោបាយគ្រប់គ្រាន់, STEPHAN TRECHSEL, HUMAN RIGHTS IN CRIMINAL PROCEEDINGS 214 (Oxford University Press, 2005) (បញ្ជាក់បន្ថែម) ។